(ខ) ក្នុងករណីលើកលែង ទីដែលវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា មិនត្រូវបានផ្តល់ឱ្យនៅកំឡុងពេលនាំចេញ ឬ ក្នុងរយៈពេលបី (៣)ថ្ងៃ នៃថ្ងៃធ្វើការចាប់ពីថ្ងៃទំនិញចុះកប៉ាល់ដោយសារតែកំហុសអចេតនា ឬ ការភ្លេចភ្លាំង ឬ ដោយមូលហេតុត្រឹមត្រូវដទៃទៀត វិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាអាចត្រូវបានផ្តល់ឱ្យដោយប្រតិសកម្ម ប៉ុន្តែមិនឱ្យហួសរយៈពេលដប់ពីរ (១២)ខែឡើយ ចាប់ពីថ្ងៃទំនិញចុះកប៉ាល់ដោយសម្គាល់ពាក្យថា "ផ្តល់ឱ្យជាប្រតិសកម្ម (ISSUED RETROACTIVELY) "។

## មាត្រា ១១

(ក) ថ្វីបើមានកថាខ័ណ្ឌ (ខ) នៃមាត្រា ៧ មាត្រា ១៣ និង១៤ (ខ) អាជ្ញាធរផ្តល់វិញ្ញាបនប័ត្រប្រភពដើម នៃភាគីអន្តរការី អាចផ្តល់វិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាថ្មីឡើងវិញ (a back-to-back C/O) បើសិនពាក្យស្នើសុំធ្វើឡើងដោយអ្នកនាំចេញនៃភាគីអន្តរការីនោះ ខណៈដែលផលិតផលកំពុងឆ្លងកាត់ទឹកដីរបស់ភាគីនោះបានចែងថា :

(១) សុពលភាពវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា មកពីភាគីនាំ-ចេញ ដើមត្រូវបានបង្ហាញជូនតែទៅអាជ្ញាធរផ្តល់វិញ្ញាបនប័ត្រប្រភពដើម នៃភាគីអន្តរការីប៉ុណ្ណោះ។

(២) អ្នកនាំចូលនៃភាគីអន្តរការី និងអ្នកនាំចេញដែលដាក់ពាក្យសុំវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ថ្មីឡើងវិញនៅក្នុងភាគីអន្តរការីគឺដូចគ្នា។

(៣) សុពលភាព នៃវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ថ្មីឡើងវិញ (back-to-back CO) នឹងមានកាលបរិច្ឆេទចុងក្រោយដូចគ្នាវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន- ឥណ្ឌា ដើម។

(៤) ការនាំចេញបន្តនូវទំនិញប្រភពដើមអាចជាទំនិញប្រភពដើមទាំងមូល ឬ ផ្នែកខ្លះនៃការដឹកជញ្ជូនទំនិញដើម។

(៥) ការដឹកជញ្ជូនទំនិញដែលត្រូវបាននាំចេញបន្ត ដោយការប្រើប្រាស់វិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ថ្មីឡើងវិញមិនត្រូវទទួលរងនូវដំណើរការកែច្នៃណាមួយបន្ថែមនៅក្នុងភាគីអន្តរការីឡើយ លើកលែងតែសម្រាប់ការវេចខ្ចប់ឡើងវិញ និងសកម្មភាពដឹកជញ្ជូន អនុលោមតាមវិធានទី ៨ នៃវិធានប្រភពដើម ។

(៦) ផលិតផលនឹងរក្សាទុកនៅក្នុងដែនដីគយនៃភាគីអន្តរការី បូករួមទាំងតំបន់ពាណិជ្ជកម្មសេរីរបស់ខ្លួន និងតំបន់បានកំណត់ដោយបានឯកភាពពីគយ។ ផលិតផលនឹងមិនត្រូវបានយកមកធ្វើពាណិជ្ជកម្ម ឬ ប្រើប្រាស់នៅក្នុងភាគីអន្តរការីនោះទេ។

(៧) ព័ត៌មានស្តីពីវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ថ្មីឡើងវិញត្រូវរាប់បញ្ចូលទាំងឈ្មោះរបស់ភាគី ដែលបានផ្តល់វិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា កាលបរិច្ឆេទនៃការផ្តល់ និងលេខយោង។ និង

(៨) ការផ្ទៀងផ្ទាត់នីតិវិធីនានាដែលបានចែងក្នុងមាត្រា ១៦ និង ១៧ ត្រូវបានអនុវត្ត។

(ខ) ភាគីនាំចេញដើម ភាគីអន្តរការី និងភាគីនាំចូលនឹងធ្វើសហប្រតិបត្តិការក្នុងដំណើរនៃការផ្ទៀងផ្ទាត់។ ការថតចម្លងវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា បានផ្តល់ឱ្យដោយភាគីនាំចេញដើម នឹងត្រូវបានប្រគល់ឱ្យទៅអាជ្ញាធរគយនៃភាគីនាំចូល បើសិនខ្លួនស្នើសុំសម្រាប់កំឡុងពេល នៃដំណើរការដូចគ្នានៃការផ្ទៀងផ្ទាត់។

(គ) នៅពេលមានសំណើរបស់ភាគីមួយ ភាគីដទៃទៀតនឹងធ្វើការត្រួតពិនិត្យឡើងវិញនូវបទប្បញ្ញត្តិទាំងឡាយនៃមាត្រានេះ និងការអនុវត្តនូវបទប្បញ្ញតិទាំងនោះ និងធ្វើការកែសម្រួលបញ្ហានេះដែលអាចឈានទៅដល់ការឯកភាពគ្នាទៅវិញទៅមកដោយបណ្តាភាគីទាំងអស់។

## មាត្រា ១២

នៅក្នុងហេតុការណ៍ដែលត្រូវចោរលួច បាត់បង់ ឬ បំផ្លិចបំផ្លាញនៃវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា អ្នកនាំចេញអាចដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរផ្តល់វិញ្ញាបនប័ត្រប្រភពដើម ដែលបានផ្តល់ឱ្យវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា សម្រាប់បញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនៃសន្លឹកដើម និងសន្លឹកទីបីដែលត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានឯកសារនាំចេញជាកម្មសិទ្ធរបស់ពួកគេដោយបញ្ជាក់ថា "បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម (CERTIFIED TRUE COPY )" (ជំនួសឱ្យវិញ្ញាបនប័ត្រដើម) នៅក្នុងប្រអប់ទី ១២។ ការថតចម្លងនេះនឹងមានចុះថ្ងៃខែទុក នៃវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា។ វិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ដែលបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនឹងត្រូវបានផ្តល់ឱ្យនៅក្នុងរយៈពេលមានសុពលភាព នៃវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាដើម ហើយស្ថិតលើលក្ខខណ្ឌដែលអ្នកនាំចេញត្រូវផ្តល់ទៅឱ្យអាជ្ញាធរផ្តល់វិញ្ញាបនប័ត្រប្រភពដើមដែលជាប់ពាក់ព័ន្ធនូវវិញ្ញាបនប័ត្រប្រភពដើមថតចម្លងសន្លឹកទី ៤។

## ការប្រគល់ឯកសារ

## មាត្រា ១៣

លើកលែងសម្រាប់តែវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ដែលបានចែងនៅក្នុងមាត្រា ១១ (ក) វិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាដើម នឹងត្រូវដាក់ជូនទៅអាជ្ញាធរគយនៅពេល នៃការដកចេញនៅច្រកនាំចូលសម្រាប់ទំនិញនោះ។

## មាត្រា ១៤

ពេលវេលាកំណត់សម្រាប់ការបង្ហាញវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា នឹងត្រូវបានអង្កេតដូចតទៅ ៖

(ក) វិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា នឹងមានសុពលភាពរយៈពេល១២ខែ ចាប់ពីកាលបរិច្ឆេទនៃការផ្តល់ឱ្យ។

(ខ) វិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា នឹងត្រូវដាក់ជូនទៅអាជ្ញាធរគយនៃភាគីនាំចូលនៅមានសុពលភាព។

(គ) ទីដែលវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ត្រូវបានដាក់ជូនទៅអាជ្ញាធរគយពាក់ព័ន្ធនៃភាគីនាំចូល បន្ទាប់ពីការផុតកំណត់សុពលភាពរបស់វា វិញ្ញាបនប័ត្រនោះនឹងនៅតែត្រូវបានទទួលស្គាល់ បើសិនកំណត់ពេលវេលាធ្វើការអង្កេតមានការខកខាន ដូចជាលទ្ធផលមកពីហេតុការណ៍ដែលពុំអាចដឹងមុន ឬ មកពីមូលហេតុផ្សេងៗទៀត បន្ទាប់ពីការត្រួតពិនិត្យរបស់អ្នកនាំចេញ។ និង

(ឃ) រាល់ករណីទាំងអស់អាជ្ញាធរគយដែលជាប់ពាក់ព័ន្ធនៅក្នុងភាគីនាំចូលអាចទទួលយកវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា បានចែងថាទំនិញត្រូវបាននាំចូលមកមុនពេលផុតកំណត់សុពលភាព នៃវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ។

## មាត្រា ១៥

(ក) នៅពេលប្រភពដើមនៃផលិតផលមួយពុំមានមន្ទិលសង្ស័យ ការរកឃើញភាពមិនស្របគ្នា បន្ទាប់បន្សំ រវាងរបាយការណ៍ដែលធ្វើនៅក្នុងវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា និងរបាយការណ៍បានធ្វើនៅក្នុងឯកសារបានដាក់ជូនអាជ្ញាធរគយនៃភាគីនាំចូលត្រួតពិនិត្យក្នុងគោលបំណង ដើម្បីអនុវត្តនូវទម្រង់ការនានាសម្រាប់ការនាំចូលផលិតផលនឹងមិនបដិសេធន៍នូវវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាឡើយ បើសិនឆ្លើយតបជាការពិតទៅលើផលិតផលនោះ។

(ខ) សម្រាប់ពហុមុខទំនិញបានប្រកាសក្រោមវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាតែមួយ បញ្ហាបានជួបប្រទះលើមុខទំនិញមួយនៅក្នុងបញ្ជីនឹងមិនជះឥទ្ធិពល ឬ ពន្យាការផ្តល់ឱ្យប្រព្រឹត្តកម្មអនុគ្រោះពន្ធគយ និងលិខិតបង់ពន្ធគយនៃមុខទំនិញនៅសេសសល់បានចុះបញ្ជីនៅក្នុងវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌានោះទេ។ កថាខ័ណ្ឌរងក (៣) នៃមាត្រា ១៦ អាចត្រូវបានអនុវត្តចំពោះបញ្ហាពហុមុខទំនិញនោះ។

## ការផ្ទៀងផ្ទាត់

## មាត្រា ១៦

(ក) ភាគីនាំចូលអាចធ្វើការស្នើសុំការត្រួតពិនិត្យប្រតិសកម្មដោយចៃដន្យ និង/ឬ នៅពេលខ្លួនមានហេតុផលសង្ស័យ អំពីភាពពិតនៃឯកសារ ឬ អំពីភាពត្រឹមត្រូវនៃព័ត៌មាន ចំពោះ ប្រភពដើមពិតនៃទំនិញនៅក្នុងការស្នើសុំ ឬ ផ្នែកខ្លះនៃប្រភពដើមទំនិញនោះ។ អាជ្ញាធរផ្តល់វិញ្ញាបនប័ត្រប្រភពដើមនឹងធ្វើការត្រួតពិនិត្យជាប្រតិសកម្មជាមួយរបាយការណ៍ថ្លៃដើម របស់ផលិតករ/ថ្លៃដើមរបស់អ្នកនាំចេញ ដោយផ្អែកលើថ្លៃ និងថ្លៃដើមបច្ចុប្បន្នក្នុងរយៈពេលប្រាំមួយ (៦)ខែ តាមគម្រោងពេលវេលាទៅនឹងកាលបរិច្ឆេទ នៃការនាំចេញដោយអាស្រ័យលើនីតិវិធីដូចតទៅ :

(១) សំណើសម្រាប់ការត្រួតពិនិត្យប្រតិសកម្ម នឹងត្រូវអមជាមួយវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាជាប់ទាក់ទង ហើយការបញ្ជាក់ឱ្យច្បាស់នូវហេតុផល និងព័ត៌មានបន្ថែមណាមួយ បានស្នើថាសេចក្តីលំអិតបានផ្តល់នៅក្នុងវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាអាចមិនត្រឹមត្រូវ លើកលែងតែការត្រួតពិនិត្យប្រតិ-សកម្មត្រូវបានស្នើសុំលើមូលដ្ឋានមិនច្បាស់លាស់។

(២) អាជ្ញាធរផ្តល់វិញ្ញាបនប័ត្រប្រភពដើមនឹងឆ្លើយតបតាមសំណើជាបន្ទាន់ និងក្នុងរយៈពេលបី (៣)ខែ បន្ទាប់ពីបានទទួលសំណើសម្រាប់ការត្រួតពិនិត្យប្រតិសកម្មមក។

(៣) ក្នុងករណីមានមន្ទិលសង្ស័យសមហេតុផលអំពីភាពពិត ឬ ភាពត្រឹមត្រូវនៃឯកសារអាជ្ញាធរគយ នៃភាគីនាំចូលអាចបញ្ឈប់ជាបណ្តោះអាសន្ននូវប្រព្រឹត្តកម្មអនុគ្រោះពន្ធគយ កំឡុងពេលរង់ចាំលទ្ធផលនៃការផ្ទៀងផ្ទាត់។ ទោះបីយ៉ាងណាគេអាចអនុញ្ញាតបញ្ចេញទំនិញទៅឱ្យអ្នកនាំចូល អាស្រ័យនូវវិធានការរដ្ឋបាលណាមួយចាំបាច់ដោយបានកំណត់ថា ពួកគេមិនត្រូវបានឃាត់ឃាំង ឬ កំហិតការនាំចូល ហើយមិនមានក្តីមន្ទិលសង្ស័យពីការលួចបន្លំឡើយ។ និង

(៤) ដំណើរការការត្រួតពិនិត្យប្រតិសកម្ម បូករួមទាំងដំណើរការជាក់ស្តែង និងការកំណត់ថា តើទំនិញចេញពីប្រភពដើម ឬ មិនមែនគួរតែត្រូវបានបំពេញសព្វគ្រប់ ហើយលទ្ធផលបានទំនាក់ទំនងទៅអាជ្ញាធរផ្តល់វិញ្ញាបនប័ត្រ នៅក្នុងរយៈពេលប្រាំមួយ (៦)ខែ។ កំឡុងពេលដំណើរការនៃការត្រួតពិនិត្យប្រតិសកម្មកំពុងដំណើរការកថាខ័ណ្ឌរង (៣) នឹងត្រូវបានយកមកអនុវត្ត។

(ខ) អាជ្ញាធរគយនៃភាគីនាំចូលអាចស្នើសុំដល់អ្នកនាំចូលនូវព័ត៌មាន ឬ ឯកសារនានាជាប់ទាក់ទងទៅនឹងប្រភពដើមទំនិញនាំចូលដោយអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួនមុនការស្នើសុំការត្រួតពិនិត្យប្រតិសកម្ម យោងតាមកថាខ័ណ្ឌ (ក)។

## មាត្រា ១៧

(ក) បើសិនភាគីនាំចូលមិនពេញចិត្តជាមួយលទ្ធផលនៃការត្រួតពិនិត្យប្រតិសកម្ម ក្រោមកាលៈទេសៈលើកលែងភាគីនោះអាចស្នើសុំពិនិត្យបញ្ជាក់ទៅភាគីនាំចេញ។ រយៈពេលពិនិត្យបញ្ជាក់ :

(១) ភាគីនាំចូល នឹងបញ្ជូនការជូនដំណឹងពីបំណងរបស់ខ្លួនទៅធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់តាមរយៈច្រកគយរួមមួយ ឬ អាជ្ញាធរសមស្របដទៃណាមួយទៀត :

១. ផលិតករ/អ្នកនាំចេញ ដែលត្រូវបានគេសន្មត់ថាបានត្រូវត្រួតពិនិត្យ។

២. អាជ្ញាធរផ្តល់វិញ្ញាបនប័ត្រនៃភាគីនៅក្នុងទឹកដី ដែលដំណើរការត្រួតពិនិត្យផ្ទៀងផ្ទាត់ត្រូវបានកើតឡើងនៅទីនោះ។

៣. ច្រកគយរួម ឬ អាជ្ញាធរសមស្របដទៃណាមួយទៀតនៃភាគីនៅក្នុងទឹកដីដែលដំណើរការត្រួតពិនិត្យផ្ទៀងផ្ទាត់ត្រូវកើតឡើងនៅទីនោះ។ និង

៤. អ្នកនាំចូលទំនិញ ជាប្រធានបទដំណើរការត្រួតពិនិត្យផ្ទៀងផ្ទាត់។

(២) សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបានរៀបរាប់នៅក្នុងកថាខ័ណ្ឌរង (១) នឹងមានលទ្ធភាពទូលំទូលាយ និងអាចរាប់បញ្ចូល :

១. ឈ្មោះច្រកគយរួម ឬ អាជ្ញាធរសមស្របដទៃណាមួយទៀត ដែលផ្តល់ឱ្យសេចក្តីជូនដំណឹង។

២. ឈ្មោះផលិតករ/អ្នកនាំចេញ ដែលត្រូវបានគេសន្មត់ថាមកធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់។

៣. កាលបរិច្ឆេទស្នើសុំសម្រាប់ដំណើរការត្រួតពិនិត្យផ្ទៀងផ្ទាត់។

៤. វិសាលភាពគ្របដណ្តប់/គោលបំណង នៃសំណើសម្រាប់ដំណើរការត្រួតពិនិត្យផ្ទៀងផ្ទាត់ បូករួមទាំងទំនិញត្រូវធ្វើការផ្ទៀងផ្ទាត់។ និង

៥. ឈ្មោះ និងតួនាទីរបស់មន្ត្រី ដែលចុះប្រតិបត្តិដំណើរការត្រួតពិនិត្យផ្ទៀងផ្ទាត់។

(៣) ភាគីនាំចូលមួយ នឹងទទួលបានសេចក្តីយល់ព្រមជាលាយលក្ខណ៍អក្សរពីផលិតករ/អ្នកនាំចេញដែលត្រូវបានគេសន្មត់មកធ្វើត្រួតពិនិត្យ។

(៤) នៅពេល សេចក្តីយល់ព្រមជាលាយល័ក្ខអក្សរមួយ មកពីផលិតករ/អ្នកនាំចេញមិនបានទទួលក្នុងរយៈពេលសាមសិប (៣០)ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃការទទួលការជូនដំណឹងស្របតាមកថាខ័ណ្ឌរង (១) ភាគីធ្វើការជូនដំណឹងអាចបដិសេធន៍ចោលប្រព្រឹត្តកម្មអនុគ្រោះពន្ធគយចំពោះទំនិញ ដែលបានអះអាងនៅក្នុងវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្ម សេរីអាស៊ាន-ឥណ្ឌា ដែលនឹងត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់។ និង

(៥) អាជ្ញាធរផ្តល់វិញ្ញាបនប័ត្រប្រភពដើមទទួលការជូនដំណឹង អាចពន្យារសំណើសុំធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងជូនដំណឹងទៅភាគីនាំចូលពីគោលបំណងនោះក្នុងរយៈពេលដប់ប្រាំ (១៥)ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃការទទួលការជូនដំណឹងនោះ។ ថ្វីបើមានការពន្យាពេលណាមួយក៏ដោយការត្រួតពិនិត្យផ្ទៀងផ្ទាត់នឹងត្រូវធ្វើឡើង ក្នុងរយៈពេលហុកសិប (៦០)ថ្ងៃ ចាប់

ពីកាលបរិច្ឆេទនៃការទទួល ឬ ក្នុងរយៈពេលវែងជាងតាមការឯកភាពគ្នារវាងបណ្តាភាគីទាំងអស់។

(ខ) ភាគីនាំចូលធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់នឹងផ្តល់ដល់ផលិតករ/អ្នកនាំចេញ ដែលទំនិញនឹងធ្វើការផ្ទៀងផ្ទាត់ និងអាជ្ញាធរផ្តល់វិញ្ញាបនប័ត្រប្រភពដើមជាប់ពាក់ព័ន្ធជាមួយការបញ្ជាក់លាយលក្ខណ៍អក្សរ ថាតើកម្មវត្ថុនៃទំនិញស្របតាមគុណភាពប្រភពដើមទំនិញ ឬ មិនស្របតាម។

(គ) ការបញ្ជាក់ថា តើទំនិញមានគុណសម្បត្តិគ្រប់គ្រាន់ជាទំនិញប្រភពដើម នឹងត្រូវជូនដំណឹងទៅផលិតករ/អ្នកនាំចេញ និងអាជ្ញាធរផ្តល់វិញ្ញាបនប័ត្រប្រភពដើមជាប់ពាក់ព័ន្ធ។ ប្រព្រឹត្តកម្មពន្ធគយអនុគ្រោះ ដែលព្យួរបណ្តោះអាសន្នណាមួយនឹងត្រូវបានប្រព្រឹត្តកម្មអនុគ្រោះពន្ធគយដូចដើមវិញបន្ទាប់ពីការបញ្ជាក់ខាងលើថា ទំនិញមានគុណសម្បត្តិគ្រប់គ្រាន់ជាទំនិញប្រភពដើម។

(ឃ) បើសិនទំនិញ ត្រូវបានបញ្ជាក់ថាពុំមានប្រភពដើមផលិតករ/អ្នកនាំចេញ នឹងត្រូវផ្តល់ឱ្យក្នុងរយៈពេលសាមសិប (៣០)ថ្ងៃចាប់ពីកាលបរិច្ឆេទនៃការទទួលសេចក្តីការបញ្ជាក់ជាលាយលក្ខណ៍អក្សរដើម្បីផ្តល់នូវយោបល់ជាលាយលក្ខណ៍អក្សរ ឬ ព័ត៌មានបន្ថែមចំពោះសិទ្ធិទទួលបានប្រព្រឹត្តកម្មពន្ធគយអនុគ្រោះចំពោះទំនិញនោះ។ បើសិនទំនិញនោះនៅតែរកឃើញថាពុំមានប្រភពដើមសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរចុងក្រោយបានផ្តល់ឱ្យដោយភាគីនាំចូល នឹងត្រូវធ្វើទំនាក់ទំនងទៅអាជ្ញាធរផ្តល់វិញ្ញាបនប័ត្រប្រភពដើម ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃចាប់ពីកាលបរិច្ឆេទនៃការទទួលមតិយោបល់/ព័ត៌មានបន្ថែមពីផលិតករ/អ្នកនាំចេញ។

(ង) ដំណើរការត្រួតពិនិត្យផ្ទៀងផ្ទាត់ រាប់បញ្ចូលទាំងត្រួតពិនិត្យជាក់ស្តែង និងសេចក្តីបញ្ជាក់ថា តើទំនិញនោះត្រូវ ឬ មិនត្រូវផ្ទៀងផ្ទាត់ប្រភពដើម ឬទេ នឹងត្រូវធ្វើការត្រួតពិនិត្យ ហើយលទ្ធផលពីការធ្វើទំនាក់ទំនងរបស់ខ្លួន ទៅអាជ្ញាធរផ្តល់វិញ្ញាបនប័ត្រប្រភពដើមក្នុងរយៈពេលអតិបរមាប្រាំមួយ (៦)ខែ ចាប់ពីកាលបរិច្ឆេទនៅពេលការត្រួតពិនិ្យផ្ទៀងផ្ទាត់បានត្រូវអនុវត្ត។ កំឡុងពេលដំណើរការផ្ទៀងផ្ទាត់កំពុងត្រូវបានធ្វើកថាខ័ណ្ឌរង ក (៣) នៃ មាត្រា ១៦ នឹងត្រូវយកមកអនុវត្ត។

## មាត្រា ១៨

(ក) ពាក្យស្នើសុំវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា និងរាល់ឯកសារទាំងឡាយ ដែលជាប់ពាក់ព័ន្ធដល់ពាក្យស្នើសុំនោះនឹងត្រូវបានរក្សាទុកដោយអាជ្ញាធរផ្តល់វិញ្ញាបនប័ត្រប្រភពដើមក្នុងរយៈពេលមិនតិចជាងពីរ (២)ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការផ្តល់វិញ្ញាបនប័ត្រប្រភពដើម។

(ខ) ព័ត៌មានដែលទាក់ទងនឹងសុពលភាព នៃវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា នឹងត្រូវបានផ្តល់ឱ្យនៅពេលមានសំណើរបស់ភាគីនាំចូល។

(គ) ព័ត៌មានណាមួយមានទំនាក់ទំនង រវាងអាជ្ញាធរជាប់ពាក់ព័ន្ធនានា នឹងត្រូវបានចាត់ទុកជារឿងសម្ងាត់ ហើយនឹងត្រូវបានប្រើប្រាស់សម្រាប់សុពលភាព នៃវិញ្ញាបនប័ត្រប្រភពដើមតាមគោលបំណង តែប៉ុណ្ណោះ។

## ករណីពិសេស
## មាត្រា ១៩

នៅពេលគោលដៅទាំងអស់ ឬ ផ្នែកនៃផលិតផលបាននាំចេញទៅកាន់កំពង់ផែជាក់លាក់ នៃភាគីមួយដែលបានផ្លាស់ប្តូរមុន ឬ បន្ទាប់ពីការមកដល់នៅក្នុងភាគីនាំចូលវិធានដូចតទៅនឹងត្រូវបានធ្វើការអង្កេត :

(ក) បើសិន ផលិតផលត្រូវបានដាក់ជូនទៅអាជ្ញាធរគយត្រួតពិនិត្យរួចរាល់នៅក្នុងភាគីនាំចូល ដែលបានបញ្ជាក់យោងតាមពាក្យស្នើសុំជាលាយលក្ខណ៍អក្សររបស់អ្នកនាំចូល វិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា នឹងត្រូវទទួលយល់ព្រមយកទាំងអស់ ឬ ផ្នែកណាមួយដោយអាជ្ញាធរខាងលើ ហើយសន្លឹកដើមត្រូវបញ្ជូនត្រឡប់ទៅអ្នកនាំចូលវិញ។

(ខ) បើសិនការផ្លាស់ប្តូរគោលដៅកើតមានឡើង ក្នុងកំឡុងពេលការដឹកជញ្ជូនទៅកាន់ភាគីនាំចូលដូចបានបញ្ជាក់នៅក្នុងវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា អ្នកនាំចេញនឹងត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ដែលអមដោយវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ដែលបានផ្តល់ឱ្យសម្រាប់ការផ្តល់ឱ្យនូវវិញ្ញាបនប័ត្រប្រភពដើមថ្មីសម្រាប់គ្រប់ផលិតផលទាំងមូល ឬ ផ្នែកនៃផលិតផលនោះ។

## មាត្រា ២០

ដើម្បីអនុវត្តវិធានទី ៨ (គ) នៃវិធានប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា កន្លែងដឹកជញ្ជូនត្រូវឆ្លងកាត់ទឹកដី នៃភាគីពុំមែនជាភាគីតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាមួយ ឬ ច្រើនខាងក្រោមនេះ នឹងបង្ហាញដល់អាជ្ញាធរគយនៃភាគីនាំចូល :

(ក) វិក័យប័ត្រដឹកជញ្ជូនមួយដែលផ្តល់ឱ្យនៅក្នុងភាគីនាំចេញ។

(ខ) វិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា មួយបានផ្តល់ឱ្យពីអាជ្ញាធរផ្តល់វិញ្ញាបនប័ត្រប្រភពដើមដែលជាប់ពាក់ព័ន្ធនៃភាគីនាំចេញ។

(គ) ការថតចំលងនៃវិក័យប័ត្រពាណិជ្ជកម្មដើម នៃទំនិញនោះ។

(ឃ) ឯកសារយោងដែលជាប់ពាក់ព័ន្ធផ្សេងៗទៀតបើមាន ជាភស្តុតាងថាអ្វីៗតម្រូវឱ្យមានតាមវិធានទី ៨ (គ) នៃវិធានប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា កំពុងត្រូវបានអនុវត្តតាម។

## មាត្រា ២១

(ក) ផលិតផលទាំងអស់បានផ្ញើចេញពីភាគីមួយ សម្រាប់ការដាក់តាំងបង្ហាញពិព័រណ៍នៅក្នុងភាគីម្ខាងទៀត ហើយត្រូវបានលក់កំឡុងពេល ឬ បន្ទាប់ពីការដាក់តាំងបង្ហាញពិព័រណ៍នឹងទទួលបានអត្ថប្រយោជន៍ពីប្រព្រឹត្តកម្មពន្ធគយអនុគ្រោះ បើសិនផលិតផលទាំងនោះបានបំពេញលក្ខខណ្ឌនៃអ្វីៗតម្រូវឱ្យមានរបស់វិធានប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ដែលបានចែងថាផលិតផលនោះត្រូវបានបង្ហាញតាមការបំពេញរបស់អាជ្ញាធរគយ ដែលជាប់ពាក់ព័ន្ធរបស់ភាគីនាំចូលថា

(១) អ្នកនាំចេញម្នាក់បានបញ្ជូនផលិតផលទាំងនោះពីទឹកដីនៃភាគីនាំចេញទៅភាគីមួយ ដែលការដាក់តាំងបង្ហាញពិព័រណ៍បានប្រារព្ធធ្វើឡើង។

(២) អ្នកនាំចេញបានលក់ផលិតផល ឬ បញ្ជូនផលិតផលទាំងនោះទៅអ្នកនាំចូលនៅក្នុងភាគីនាំចូល។ និង

(៣) ផលិតផលត្រូវបាននាំចូលកំឡុងពេលការដាក់តាំងបង្ហាញពិព័រណ៍ ឬ បន្ទាប់ពីនោះភ្លាមៗទៅកាន់ភាគីនាំចូល ក្នុងអ្វីដែលទំនិញទាំងនោះបានត្រូវបញ្ជូនទៅសម្រាប់ការតាំងបង្ហាញពិព័រណ៍។

(ខ) ដើម្បីអនុវត្តកថាខណ្ឌ (ក) វិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ត្រូវតែបង្ហាញដល់អាជ្ញាធរគយជាប់ពាក់ព័ន្ធនៃភាគីនាំចូល។ ឈ្មោះ និងអាសយដ្ឋានការតាំងបង្ហាញពិព័រណ៍ត្រូវតែបង្ហាញប្រាប់ឱ្យគេដឹង វិញ្ញាបនប័ត្រមួយដែលផ្តល់ឱ្យពីអាជ្ញាធរផ្តល់វិញ្ញាបនប័ត្រប្រភពដើម ដែលជាប់ពាក់ព័ន្ធនៃភាគីកន្លែងតាំងបង្ហាញពិព័រណ៍បានប្រព្រឹត្តទៅនៅទីនោះជាមួយគ្នាជាមួយឯកសារយោងនានាដែលបានអធិប្បាយនៅក្នុង មាត្រា ២០ (ឃ) អាចត្រូវបានគេស្នើសុំ។

(គ) កថាខណ្ឌ (ក) នឹងអនុវត្តចំពោះការតាំងបង្ហាញពិព័រណ៍ណាមួយ ពិព័រណ៍ ឬ ការតាំងបង្ហាញប្រហាក់ប្រហែល នៅក្នុងកន្លែងដែលផលិតផលរក្សាទុកនៅក្រោមការត្រួតពិនិត្យរបស់គយកំឡុងពេលព្រឹត្តិការណ៍បានកើតឡើង ។

## មាត្រា ២២

អាជ្ញាធរគយនៅក្នុងភាគីនាំចូល នឹងត្រូវទទួលយកវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ដែលវិក័យប័ត្រលក់ត្រូវបានផ្តល់ឱ្យទាំងក្រុមហ៊ុនដែលបោះទីតាំងនៅក្នុងប្រទេសទី ៣ ឬ អ្នកនាំចេញតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា សម្រាប់គណនីនៃក្រុមហ៊ុនដែលបានពោលខាងលើ ដូចបានចែងថា ទំនិញនោះបំពេញតាមលក្ខខណ្ឌនៃវិធានប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា។

## សកម្មភាពប្រឆាំងអំពើលួចក្លែងបន្លំ
## មាត្រា ២៣

(ក) នៅពេលមានការសង្ស័យអំពើលួចក្លែងបន្លំ ទាក់ទងទៅនឹងវិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជ-កម្មសេរីអាស៊ាន-ឥណ្ឌា ត្រូវបានគេប្រព្រឹត្តឡើងអាជ្ញាធររដ្ឋាភិបាលជាប់ពាក់ព័ន្ធនឹងធ្វើសហប្រតិបត្តិជាសកម្មភាពណាមួយប្រឆាំងទល់បុគ្គលជាប់ពាក់ព័ន្ធបញ្ហាទាំងនោះ។

(ខ) ភាគីនីមួយៗ នឹងទទួលខុសត្រូវក្នុងការដាក់ទណ្ឌកម្មស្របច្បាប់ប្រឆាំងទល់អំពើលួចក្លែងបន្លំដែលជាប់ទាក់ទងដល់វិញ្ញាបនប័ត្រប្រភពដើមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា។

## មាត្រា ២៤

(ក) ក្នុងករណីជម្លោះជាប់ទាក់ទងការបញ្ជាក់ពីប្រភពដើមចំណាត់ថ្នាក់ផលិតផល ឬបញ្ហាជាប់ពាក់ព័ន្ធដទៃទៀត អាជ្ញាធររដ្ឋាភិបាលជាប់ពាក់ព័ន្ធជាមួយភាគីនាំចេញ និងភាគីនាំចូលនឹងធ្វើការពិគ្រោះយោបល់ជាមួយគ្នា ក្នុងទស្សនៈដើម្បីដោះស្រាយជម្លោះ ហើយលទ្ធផលនឹងត្រូវបានជូនដំណឹងទៅភាគីដទៃទៀតសម្រាប់ជាព័ត៌មាន។

(ខ) ដោយមិនមានការពេញចិត្តក្នុងការដោះស្រាយទៅនឹងជម្លោះ តាមរយៈការពិគ្រោះយោបល់ ភាគីជាប់ពាក់ព័ន្ធអាចយកនីតិវិធីដោះស្រាយជម្លោះនៅក្រោមកិច្ចព្រមព្រៀង ស្តីពីយន្តការដោះស្រាយជម្លោះអាស៊ាន-ឥណ្ឌា។

ឧបសម្ព័ន្ធ ១ ចំពោះ និតិវិធីបញ្ជាក់នូវប្រតិបត្តិការ

ច្បាប់ដើម (ទុតិយតា តតិយតា ចតុត្ថគុណ)ប

លេខអំណះអំណាង

តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា
ពន្ធអនុគ្រោះ
វិញ្ញាបនប័ត្រប្រភពដើម
(វិញ្ញាបនប័ត្រ និង ប្រតិវេទន៍រួម)

ទម្រង់ AI

ផ្តល់ឱ្យនៅ ____________
(ប្រទេស)
មើលលើទំព័រម្ខាងទៀត

១ ទំនិញនាំចូលមកពី (ឈ្មោះអ្នកនាំចេញ, អាសយដ្ឋាន, ប្រទេស)

២ ទំនិញនាំទៅកាន់ (ឈ្មោះអ្នកនាំចូល, អាសយដ្ឋាន, ប្រទេស)

៣ មធ្យោបាយដឹកជញ្ជូន និងផ្លូវធ្វើដំណើរ

កាលបរិច្ឆេទចាកចេញ:........

ឈ្មោះនាវា/យន្តហោះ។ល។:............

កំពង់ផែចាកចេញ:..........

៤. សំរាប់មន្ត្រីប្រើប្រាស់

☐ ប្រព្រឹត្តកម្មអនុគ្រោះ ដែលផ្តល់ឱ្យនៅក្រោម ពន្ធអនុគ្រោះ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា

☐ ប្រព្រឹត្តកម្មអនុគ្រោះដែលពុំបានផ្តល់ឱ្យ (បញ្ជាក់ពីមូលហេតុ)

.................................................................................................

ហត្ថលេខានៃហត្ថលេខីដែលទទួលបានសិទ្ធិ នៃប្រទេសនាំចូល

| ៥. លេខ | ៦.សញ្ញា | ៧. លេខ និង ប្រភេទកញ្ចប់ | ៨. ការវិនិច្ឆ័យប្រភពដើម | ៩. ទម្ងន់សរុប ឬ | ១០. លេខវិក័យប័ត្រ |
|---|---|---|---|---|---|
| ចំនុច ទំនិញ | និង លេខ លើកញ្ចប់ | ការពិពណ៌នាមុខទំនិញ (រួមទាំង បរិមាណ និង លេខសុខដុមនីយកម្ម នៃប្រទេសនាំចូល) | (មើលលើទំព័រម្ខាងទៀត) | បរិមាណ និង តម្លៃដទៃទៀត (FOB) | និង កាលបរិច្ឆេទ |
| | | | | | |

១១ ប្រតិវេទន៍អ្នកនាំចេញ

ហត្ថលេខាខាងក្រោម បញ្ជាក់ថា ទំនិញទាំងអស់ បានផលិតនៅ

.................................................................
(ប្រទេស)

ពិតប្រាកដមែន
ហើយទំនិញទាំងអស់បានបំពេញតាមលក្ខខ័ណ្ឌប្រភពដើម
ដែលបានបញ្ជាក់សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា
សំរាប់ទំនិញនាំចេញដែលទទួលបានប្រព្រឹត្តកម្មអនុគ្រោះ

.................................................................
(ប្រទេសនាំចូល)

.................................................................
ទីកន្លែង និង កាលបរិច្ឆេទ, ហត្ថលេខា នៃហត្ថលេខីដែលបានទទួលសិទ្ធិ

១២. លិខិតបញ្ជាក់

យោងតាមការអនុវត្តការត្រួតពិនិត្យ, បញ្ជាក់ថា ប្រតិវេទន៍ពីអ្នកនាំចេញពិតជាត្រឹមត្រូវប្រាកដមែន

.................................................................
ទីកន្លែង និង កាលបរិច្ឆេទ, ហត្ថលេខា និងត្រាអាជ្ញាធរផ្តល់វិញ្ញាបនប័ត្រ

១៣. សូមចុចត្រង់កន្លែងសមគួរ:

☐ ធ្វើវិក័យប័ត្រនៅប្រទេសទីបី ☐ ការតាំងបង្ហាញពិព័រណ៍ ☐ វិញ្ញាបនប័ត្រប្រភពដើមទល់ខ្នងគ្នា ☐ ផលប្តូរត្រូត

កំណត់សម្គាល់នៅលើទំព័រម្ខាងទៀត:

១ បណ្តាភាគីទាំងអស់ ដែលយល់ស្របតាមទម្រង់នេះ ដើម្បីទទួលបានពន្ធអនុគ្រោះនៅក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា រួមមាន

| | | |
|---|---|---|
| ប្រុយណេ | កម្ពុជា | ឥណ្ឌូនេស៊ី |
| ឥណ្ឌា | ឡាវ | ម៉ាឡេស៊ី |
| មីយ៉ាន់ម៉ា | ហ្វីលីពីន | សិង្ហបុរី |
| ថៃឡង់ | វៀតណាម | |

២ លក្ខខ័ណ: ដើម្បីទទួលបានពន្ធអនុគ្រោះនៅក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា, ទំនិញដែលបានបញ្ជូនទៅភាគីណាមួយ ដែលបានចុះឈ្មោះ ដូចខាងលើ:

(១) ត្រូវតែស្ថិតនៅក្នុងការរ៉ាយរ៉ាប់មុខទំនិញ ដែលអាចទទួលបានសម្បទាននៅក្នុងប្រទេសនាំចូល
(២) ត្រូវតែប្រព្រឹត្តតាមលក្ខខ័ណបញ្ជូនទំនិញ អនុលោមតាមវិធានទី ៨ វិធានប្រភពដើមអាស៊ាន-ឥណ្ឌា, និង
(៣) ត្រូវតែប្រព្រឹត្តតាមការវិនិច្ឆ័យប្រភពដើមនៅក្នុងវិធានប្រភពដើម សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា

៣ ការវិនិច្ឆ័យប្រភពដើម: សំរាប់ទំនិញដែលជួប ការវិនិច្ឆ័យប្រភពដើម, អ្នកនាំចេញ និង/ឬ ផលិតករ ត្រូវតែបង្ហាញនៅក្នុងប្រអប់ទី ៨ នៃទម្រង់វិញ្ញាបនប័ត្រប្រភពដើម (co From AI), ការវិនិច្ឆ័យប្រភពដើមដែលជួប, បានបង្ហាញនៅក្នុងតារាងខាងក្រោម:

| កាលៈទេសៈផលិតកម្ម ឬ កម្មន្តសាល នៅក្នុងប្រទេសដំបូង ដែលមានឈ្មោះនៅក្នុងប្រអប់ទី ១១ នៃទម្រង់វិញ្ញាបនប័ត្រប្រភពដើមនេះ: | ដាក់ចូលក្នុងប្រអប់ទី ៨ |
|---|---|
| (ក) ទំនិញដែលទទួលបាន ឬ ផលិតបានទាំងស្រុង នៅក្នុងដែនដីនៃភាគីនាំចេញ | គឺអក្សរ "WO" |
| (ខ) ទំនិញដែលបំពេញតាមវិធានទី ៤ នៃវិធានប្រភពដើម តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា | គឺអក្សរ "RVC [ ]% + CTSH" |
| (គ) ទំនិញដែលបំពេញតាមវិធានទី ៦ នៃវិធានប្រភពដើម តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា | ការវិនិច្ឆ័យយោងតាមគុណសម្បត្តិសមរម្យ |

៤ ទំនិញនីមួយៗត្រូវតែមានគុណសម្បត្តិគ្រប់គ្រាន់: វាគួរត្រូវបានគេកំណត់ថា រាល់ទំនិញទាំងអស់ក្នុងការបញ្ជូនត្រូវតែមានគុណសម្បត្តិគ្រប់គ្រាន់តាមសិទ្ធិដោយឡែកៗ របស់វាផ្ទាល់។ នេះជាការទាក់ទងជាពិសេស នៅពេលទំនិញមានទំហំខុសៗគ្នា ឬ គ្រឿងបន្លាស់ ប្រហាក់ប្រហែលគ្នា ត្រូវបានផ្ញើ។

៥. ការរ៉ាយរ៉ាប់មុខទំនិញ: ការរ៉ាយរ៉ាប់មុខទំនិញ ត្រូវតែបញ្ជាក់លំអិតឱ្យបានគ្រប់គ្រាន់ ដើម្បីទំនិញអាចត្រូវបានកំណត់អត្តសញ្ញាណច្បាស់លាស់ពីភ្នាក់ងារគយនៅពេលកំពុងត្រួតពិនិត្យទំនិញទាំងនោះ។ ឈ្មោះឧស្សាហករ, ផ្លាកសញ្ញាពាណិជ្ជកម្មណាមួយក៏នឹងត្រូវបញ្ជាក់ផងដែរ។

៦. ប្រព័ន្ធលេខកូដសុខដុម្មនីយកម្ម: ប្រព័ន្ធលេខកូដសុខដុម្មនីយកម្ម នឹងជា ប្រព័ន្ធលេខកូដសុខដុម្មនីយកម្មនៃភាគីនាំចូល ។

៧. អ្នកនាំចេញ: ពាក្យស័ព្ទ ៉អ្នកនាំចេញ ៉នៅក្នុងប្រអប់ទី ១១ អាចរួមបញ្ចូលទាំងឧស្សាហករ ឬ ផលិតករ ។

៨. សំរាប់មន្ត្រីប្រើប្រាស់: អាជ្ញាធរគយ នៃភាគីនាំចូល ត្រូវតែបង្ហាញសញ្ញា (√) នៅក្នុងប្រអប់ដែលជាប់ទាក់ទង នៅក្នុងកូឡោនទី ៤ ថាតើ ប្រព្រឹត្តកម្មពន្ធគយអនុគ្រោះត្រូវបានគេព្រមព្រៀងគ្នា ឬ មិនព្រមព្រៀងគ្នា។

៩. ធ្វើវិក័យប័ត្រនៅប្រទេសទីបី: នៅក្នុងករណីដែលវិក័យប័ត្រនានា ត្រូវបានផ្តល់ឱ្យដោយប្រទេសទីបី, ប្រអប់ ៉ធ្វើវិក័យប័ត្រនៅប្រទេសទីបី ៉គួរត្រូវដាក់សញ្ញា (√) ហើយ ព័ត៌មាន ដូចជាឈ្មោះ និង ប្រទេសនៃក្រុមហ៊ុនដែលផ្តល់វិក័យប័ត្រ នឹងត្រូវបង្ហាញនៅក្នុងប្រអប់ទី ៧ ។

១០. ការតាំងបង្ហាញពិព័ណ: នៅក្នុងករណី ដែលទំនិញត្រូវបានបញ្ជូនចេញពីដែនដីនៃភាគីនាំចេញ សំរាប់ការតាំងបង្ហាញពិព័ណ នៅក្នុងប្រទេសដទៃ និងបានលក់ដូរ កំឡុងពេល ឬ ក្រោយពេល ការតាំងបង្ហាញពិព័ណ សំរាប់ការនាំចូលទៅក្នុងដែនដីនៃភាគីមួយ , អនុលោមតាម មាត្រា ១២ នៃនិតិវិធីបញ្ជាក់នូវប្រតិបត្តិការ, ប្រអប់ ៉ការតាំងបង្ហាញពិព័ណ ៉គួរត្រូវដាក់សញ្ញា (√) ហើយឈ្មោះ និង អាសយដ្ឋាននៃ ការតាំងបង្ហាញពិព័ណ មានបង្ហាញនៅក្នុងប្រអប់ទី ២។

១១ វិញ្ញាបនប័ត្រប្រភពដើមទល់ខ្នងគ្នា: នៅក្នុងករណី វិញ្ញាបនប័ត្រប្រភពដើមទល់ខ្នងគ្នា, អនុលោមតាម មាត្រា ១១ នៃនិតិវិធីបញ្ជាក់នូវប្រតិបត្តិការ, ប្រអប់ ៉វិញ្ញាបនប័ត្រប្រភពដើមទល់ខ្នងគ្នា ៉គួរតែដាក់សញ្ញា (√)។ ឈ្មោះនៃភាគីនាំចេញដើម ត្រូវបានបង្ហាញនៅក្នុងប្រអប់ទី ១១ ហើយកាលបរិច្ឆេទនៃការផ្តល់ឱ្យវិញ្ញា បនប័ត្រប្រភពដើម និង លេខអំណះអំណាង នឹងត្រូវបង្ហាញនៅក្នុងប្រអប់ទី ១២។

( ត ទៅរាជកិច្ចលេខ ១៨)

នស/រកត/០២១១/១៥៧

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដាក់ឯកឧត្តម **មាស គឹមហេង** ឋានន្តរស័ក្តិឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ២ នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ បច្ចុប្បន្នជាអគ្គនាយកនៃអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល ០៦ខែ (ប្រាំមួយខែ) លើកទី១ គិតចាប់ពីថ្ងៃទី០១ខែកញ្ញា ឆ្នាំ២០១០ ដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួល

**មាត្រា ៤ :** អនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។
ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១១០៧. ១៦១

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១*

**លេខៈ ១៦៦ ច.ល**
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១១
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១១/១៥៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

## នូវ

## គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

## ចំពោះ

## ឯកឧត្តម ហ្សង់-ដាវីដ ឡឺវីត ( Jean-David Levitte )

ទីប្រឹក្សាការទូតរបស់ប្រធានាធិបតីបារាំង នីកូឡា សាកូហ្ស៊ី (Nicolas Sarkozy) ដែលមានស្នាដៃល្អបាន
ចូលរួមយ៉ាងសកម្ម ក្នុងការជំរុញអោយកើតមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ២៣ តុលា ១៩៩១ ទទួលបានជោគជ័យ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ១១០២. ១៦២

លេខៈ ១៦៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី២៤ខែ កុម្ភៈឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១

យុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២១១/១៥៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិ ដល់ នាយទាហាន ជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

**ក~ ដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ទោ**

១- ឧត្តមសេនីយ៍ត្រី **គួច ផេងឆាន់** អត្តលេខ ០០២១៨២
២- ឧត្តមសេនីយ៍ត្រី **អ៊ុំ ច័ាន់ថា** អត្តលេខ ០០២១៨៨
៣- ឧត្តមសេនីយ៍ត្រី **ផល សាម៉ន** អត្តលេខ ០១៧០០៨
៤- ឧត្តមសេនីយ៍ត្រី **អ៊ិន ពីឌិច** អត្តលេខ ០១៨៥២៩
៥- ឧត្តមសេនីយ៍ត្រី **អោក សៀង** អត្តលេខ ០០៩៥២០
៦- ឧត្តមសេនីយ៍ត្រី **តន់ សាលី** អត្តលេខ ០០៩៥៣០
៧- ឧត្តមសេនីយ៍ត្រី **តាំង សំបិន** អត្តលេខ ០០២១៥៩

**ខ~ ដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី**

១- វរសេនីយ៍ឯក **កែវ សាឡឿន** អត្តលេខ ០១១៨៣៦
២- វរសេនីយ៍ឯក **ឃ្លោក សារី** អត្តលេខ ០០៣៨៥៣

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣- វរសេនីយ៍ឯក **តាំង ចាន់ពន្លឺ** អត្តលេខ ០៨៥៨១៩

៤- វរសេនីយ៍ឯក **ចិន ឌី** អត្តលេខ ០០៩៥៩៦

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុក អនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១១០២.១៦៣

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១១

លេខ: ១៥៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១១/១៦០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងលោកជំទាវ **ហ៊ុន គឹមថាច** ជាទីប្រឹក្សាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.១១០២.១៦៤

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១១*

លេខ: ១៦៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**យុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១១/១៦២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

## ចំពោះ

ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន ១៣ រូប
មានស្នាដៃល្អ និងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការបំពេញភារកិច្ច ជូនរាជរដ្ឋាភិបាល

## នូវ

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

លោកជំទាវ **នន់ភានី**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១-លោក **ហ៊ីយ ផាប់**
២-លោក **ចាប់ គឹមរ៉េត**

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :**

១-លោក **កែវ សឿងសោភ័ណ**
២-លោក **ហាក់ ហឿន**
៣-លោក **ឌិត ធន**
៤-លោក **ពូន ចលនា**
៥-លោក **ហុង ឃន**

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

១-ឯកឧត្តម **គឹម កុសល**
២-ឯកឧត្តម **សាយ នីដ្ឋា**
៣-ឯកឧត្តម **ទេង សុទ្ធមុធ**
៤-លោកជំទាវ **ឌិត្យ ច័ន្ទតារីន**
៥-ឯកឧត្តម **ប៊ិន សម្បត្តិថារ័ត្ន**

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

៣រព.១១០៧.១៦៥

*ធ្វើនៅព្រះបរមរាជវាំង ,ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១*

លេខៈ ១៦៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី២៧ខែ កុម្ភៈ ឆ្នាំ២០១១
**អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/០២១១/១៦៧

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **ឡាំ ហេងហួត** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១១០២. ១៦៦

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១

លេខ: ១៥៦ ច.ល
ជើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០១១
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១១/១៦៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **ញឹក ប៊ុនឆៃ** ជាទីប្រឹក្សាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១១០២. ១៦៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១១

លេខ: ១៥៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**ឃុន ជិនកេន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៧ អនក្រ.បក

* * * * *

# អនុក្រឹត្យ

# ស្តីពី

# ការទទួលស្គាល់ វិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

* * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក. ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

# សម្រេច

## មាត្រា ១.-

ត្រូវបានទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា វិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Institute of Specialized Economics and Finance) សរសេរកាត់ជាភាសាខ្មែរ "វ.ឯ.ស.ហ" និងសរសេរកាត់ជាភាសាអង់គ្លេស "ISEF"។

## មាត្រា ២.-

វិទ្យាស្ថានឯកទេសសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានទីតាំងស្ថិតនៅ អគារលេខ ៤៤- ៤៦ និងអគារលេខ ៦០ ផ្លូវ ៣១៣ សង្កាត់បឹងកក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

## មាត្រា ៣.-

វិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការបណ្តុះបណ្តាលកម្រិត បរិញ្ញាបត្ររងរហូតដល់បរិញ្ញាបត្រជាន់ខ្ពស់ លើមហាវិទ្យាល័យ ពីរ និង មជ្ឈមណ្ឌល មួយ៖

១- មហាវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាន និងភាសា

២- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងសេដ្ឋកិច្ច

៣- មជ្ឈមណ្ឌលទីផ្សារមូលបត្រ និងសិក្សាស្រាវជ្រាវ

វិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិតតាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងចាប់ផ្តើមដំណើរការបណ្តុះបណ្តាល។ ទៅអនាគត វិទ្យាស្ថាននេះ អាចបើកសាខាមហាវិទ្យាល័យថ្មី មុខជំនាញថ្មី កម្រិត ឬ ថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ប្តូរឈ្មោះ ឬ ទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពី ក្រសួងអប់រំ យុវជន និងកីឡា ។

## មាត្រា ៤.-

វិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។ តួនាទី ភារកិច្ច រចនាសម្ព័ន្ធគ្រប់គ្រង និងការប្រព្រឹត្តទៅនៃ វិទ្យាស្ថានឯកទេសសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថាន និង មានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

## មាត្រា ៥.-

នាយកវិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ច ៖

-ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន និងជានាឲ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។

-ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិតឲ្យចូលរៀន និងទទួលនិស្សិតឲ្យសិក្សាបន្ត តាមកម្មវិធីសិក្សារបស់វិទ្យាស្ថាន ។

-គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋាន ដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាលរបស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅជានាគុណភាពអប់រំ ។

-រៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងវិទ្យាស្ថាន និងវិធានផ្ទៃក្នុង សម្រាប់ការគ្រប់គ្រងការសិក្សា ឲ្យបានច្បាស់លាស់ ស្របតាមគោលការណ៍ ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

-ធ្វើរបាយការណ៍ប្រចាំឆ្នាំ អំពីការងារបណ្តុះបណ្តាល មកក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។

## មាត្រា ៦.-

និស្សិតវិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានរៀនចប់កម្មវិធីសិក្សា និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះ ត្រូវផ្តល់ឲ្យដោយវិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីវិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ។

## មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាភិបាល រួមទាំងនាយកនៃវិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា ១..**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ ជូនមន្ត្រីរាជការ និងបុគ្គលិកសិក្សានៃមន្ទីរអប់រំ យុវជននិងកីឡាខេត្តកំពត ចំនួន០៣រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ លើវិស័យអប់រំកន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោក កៅ រិទ្ធ អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត

២-លោក តូច គា អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត

៣-លោក រ័ត្ន ម៉ៅ ប្រធានការិយាល័យ អប់រំ យុវជន និងកីឡា ស្រុកកំពង់ត្រាច

**មាត្រា ២..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ២ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៨៤៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងបុគ្គលិកសិក្សានៃមន្ទីរអប់រំយុវជន និងកីឡា ខេត្តកំពត ចំនួន៥៣៧រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិលើវិស័យអប់រំកន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក.មេដាយមាសការងារ:**

| | | | | | | |
|---|---|---|---|---|---|---|
| ១ | លោក | សូ | វុត្ថា | ប្រធានការិយាល័យ | មន្ទីរអប់រំ យុវជន និងកីឡា | ខេត្តកំពត |
| ២ | លោក | សូ | ភារិទ្ធិ | ប្រធានការិយាល័យ | មន្ទីរអប់រំ យុវជន និងកីឡា | ខេត្តកំពត |
| ៣ | លោក | ខៀវ | ធនវុឌ្ឍី | ប្រធានការិយាល័យ | មន្ទីរអប់រំ យុវជន និងកីឡា | ខេត្តកំពត |
| ៤ | លោក | មិន | ម៉ាលី | ប្រធានការិយាល័យ | មន្ទីរអប់រំ យុវជន និងកីឡា | ខេត្តកំពត |
| ៥ | លោក | គីម | សុខា | ប្រធានការិយាល័យ | មន្ទីរអប់រំ យុវជន និងកីឡា | ខេត្តកំពត |
| ៦ | លោក | ឆាយ | បូរ៉ាមី | ប្រធានការិយាល័យ | មន្ទីរអប់រំ យុវជន និងកីឡា | ខេត្តកំពត |
| ៧ | លោក | សូ | វុទ្ធី | ប្រធានការិយាល័យ | មន្ទីរអប់រំ យុវជន និងកីឡា | ខេត្តកំពត |
| ៨ | លោកស្រី | ដួង | សុវណ្ណារ៉ា | ប្រធានការិយាល័យ | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកទឹកឈូ |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | លោកស្រី | ទេស | វណ្ណា | អនុប្រធាន | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកឈូក |
| ១០ | លោក | ស្រី | សាន់ | អនុប្រធាន | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកកំពង់ត្រាច |
| ១១ | លោក | ឌុច | សុខា | អនុប្រធាន | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកកំពង់ត្រាច |
| ១២ | លោក | ណុប | សុផល | ប្រធានការិយាល័យ | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកបន្ទាយមាស |
| ១៣ | លោក | គង់ | គីមសាធ | អនុប្រធាន | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកបន្ទាយមាស |
| ១៤ | លោក | ប៉ែន | គីមហ៊ា | ប្រធានការិយាល័យ | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកជុំគីរី |
| ១៥ | លោក | សំ | យ៉ុន | នាយកសាលា | វិទ្យាល័យ ប៊ុនរ៉ានីហ៊ុនសែនដងទង់ | ស្រុកដងទង់ |
| ១៦ | លោក | ព្រហ្ម | សាមឿន | ប្រធានការិយាល័យ | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកអង្គរជ័យ |
| ១៧ | លោក | គង់ | មី | ប្រធានការិយាល័យ | ការិយាល័យអប់រំ យុវជន និងកីឡា | ក្រុងកំពត |
| ១៨ | លោក | អ៊ុង | សំអាត | នាយកសាលា | សាលាគរុកោសល្យ និងវិក្រឹតការ | ក្រុងកំពត |
| ១៩ | លោក | ម៉ែន | ម៉ុល | មន្ត្រីរដ្ឋបាល | សាលាបឋមសិក្សា ខ្សេវផៃអែមអង្គស្លុក | ស្រុកអង្គរជ័យ |
| ២០ | លោក | ចក់ | វណ្ណា | មន្ត្រីរដ្ឋបាល | សាលាបឋមសិក្សា ប្រភ្នំ | ស្រុកអង្គរជ័យ |
| ២១ | លោក | ឈន | ឡាយហេង | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកអង្គរជ័យ |
| ២២ | លោកស្រី | គីង | ម៉ាឡែត | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកអង្គរជ័យ |
| ២៣ | លោក | កុល | សុជាតិ | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកទឹកឈូ |
| ២៤ | លោក | យន | សាយ | មន្ត្រីរដ្ឋបាល | អនុវិទ្យាល័យ រលួស | ស្រុកទឹកឈូ |
| ២៥ | លោក | ងាវ | ជាន | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកទឹកឈូ |
| ២៦ | លោក | ឆាយ | ខេងស៊ាង | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកទឹកឈូ |
| ២៧ | លោក | គង់ | សង្វាត | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកទឹកឈូ |
| ២៨ | លោក | ស៊ីវ | ប៉ូ | មន្ត្រីរដ្ឋបាល | វិទ្យាល័យ ហ៊ុន សែនត្រសេកកោង | ស្រុកទឹកឈូ |
| ២៩ | លោក | បុត្រ | នឿន | មន្ត្រីរដ្ឋបាល | សាលាបឋមសិក្សា ក្តាត | ស្រុកទឹកឈូ |
| ៣០ | លោក | មែ | សារ៉ាត | មន្ត្រីរដ្ឋបាល | សាលាបឋមសិក្សា អង្គឈូក | ស្រុកឈូក |
| ៣១ | លោកស្រី | សំ | ម៉ានី | មន្ត្រីរដ្ឋបាល | វិទ្យាល័យ មាសសុភាបានៀវ | ស្រុកឈូក |
| ៣២ | លោក | ជា | ឡយ | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកឈូក |
| ៣៣ | លោក | កែវ | ឆាត | មន្ត្រីរដ្ឋបាល | អនុវិទ្យាល័យ ក្រាំងស្វាយ | ស្រុកឈូក |
| ៣៤ | លោក | គាត | សុមុត្ថា | មន្ត្រីរដ្ឋបាល | សាលាបឋមសិក្សា បានៀវ | ស្រុកឈូក |
| ៣៥ | លោក | ហេង | សេង | មន្ត្រីរដ្ឋបាល | វិទ្យាល័យ អង្គសុរភី | ស្រុកកំពង់ត្រាច |

| | | | | | | |
|---|---|---|---|---|---|---|
| ៣៦ | លោក | បាវ | យី | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកកំពង់ត្រាច |
| ៣៧ | លោក | ម៉ម | សារេត | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកកំពង់ត្រាច |
| ៣៨ | លោកស្រី | អេង | ចាន់នី | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកកំពង់ត្រាច |
| ៣៩ | លោក | ប៉ិល | ស៊ីណុច | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកកំពង់ត្រាច |
| ៤០ | លោក | ពិន | ផេង | មន្ត្រីរដ្ឋបាល | អនុវិទ្យាល័យ គាថាវង្ស | ស្រុកបន្ទាយមាស |
| ៤១ | លោកស្រី | យឹង | សារ៉ង | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកបន្ទាយមាស |
| ៤២ | លោក | សួន | សារិន | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកបន្ទាយមាស |
| ៤៣ | លោក | ទុំ | សុគន្ធារុន | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកបន្ទាយមាស |
| ៤៤ | លោក | ចាន់ | រុំ | មន្ត្រីរដ្ឋបាល | វិទ្យាល័យ ហ៊ុន សែនបរិវាស | ស្រុកបន្ទាយមាស |
| ៤៥ | លោក | តឹក | សុខឿន | មន្ត្រីរដ្ឋបាល | វិទ្យាល័យ អង្គរមាស | ស្រុកដងទង់ |
| ៤៦ | លោក | គិត | ទ្រី | មន្ត្រីរដ្ឋបាល | អនុវិទ្យាល័យ ត្រពាំងត្រាញ់ | ស្រុកដងទង់ |
| ៤៧ | លោក | គីម | វ៉ាំង | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកជុំគីរី |
| ៤៨ | លោក | ទៀប | សម្បត្តិ | មន្ត្រីរដ្ឋបាល | ការិយាល័យអប់រំ យុវជន និងកីឡា | ស្រុកជុំគីរី |
| ៤៩ | លោក | ម៉ម | ហ៊ាន | មន្ត្រីរដ្ឋបាល | អនុវិទ្យាល័យ ត្រើយកោះ | ក្រុងកំពត |
| ៥០ | លោក | ស៊ឹម | សុម៉ាថៃ | មន្ត្រីរដ្ឋបាល | អនុវិទ្យាល័យ ហ៊ុន សែនក្រាំងអំពិល | ក្រុងកំពត |
| ៥១ | លោក | មាស | បូរ៉ាត | សិក្ខាបនធារី | វិទ្យាល័យ ហ៊ុន សែនព្រែកត្នោត | ស្រុកទឹកឈូ |
| ៥២ | លោកស្រី | វង្ស | សុធា | សិក្ខាបនធារី | វិទ្យាល័យ ព្រះនរោត្តមរណឫទ្ធិ | ស្រុកទឹកឈូ |
| ៥៣ | លោក | រឿន | សារិន | សិក្ខាបនធារី | វិទ្យាល័យ ហ៊ុន សែនត្រសេកកោង | ស្រុកទឹកឈូ |
| ៥៤ | លោក | រស់ | សុផល | សិក្ខាបនធារី | អនុវិទ្យាល័យ រលួស | ស្រុកទឹកឈូ |
| ៥៥ | លោកស្រី | ជូ | សំអុល | សិក្ខាបនធារី | សាលាបឋមសិក្សា ជុំគ្រៀល | ស្រុកទឹកឈូ |
| ៥៦ | លោកស្រី | ណាវ | ចន្ទី | សិក្ខាបនធារី | សាលាបឋមសិក្សា ក្អាត | ស្រុកទឹកឈូ |
| ៥៧ | លោកស្រី | សុខ | ណារី | សិក្ខាបនធារី | សាលាបឋមសិក្សា កំពង់គ្រែង | ស្រុកទឹកឈូ |
| ៥៨ | លោក | ឈឿង | ពិន | សិក្ខាបនធារី | វិទ្យាល័យ ហ៊ុន សែនឈូក | ស្រុកឈូក |
| ៥៩ | លោក | ចាន់ | ដារ៉ា | សិក្ខាបនធារី | វិទ្យាល័យ ហ៊ុន សែនឈូក | ស្រុកឈូក |
| ៦០ | លោកស្រី | អ៊ុច | អែម | សិក្ខាបនធារី | អនុវិទ្យាល័យ ក្រាំងស្វាយ | ស្រុកឈូក |
| ៦១ | លោក | ប៉ាវ | រ៉េម | សិក្ខាបនធារី | អនុវិទ្យាល័យ ឈើទាលជ្រុំ | ស្រុកឈូក |
| ៦២ | លោក | មឿង | ធឿន | សិក្ខាបនធារី | សាលាបឋមសិក្សា ប៊ុនរ៉ានីហសនារាយណ៍ | ស្រុកឈូក |

| | | | | | | |
|---|---|---|---|---|---|---|
| ៦៣ | លោកស្រី | ទេស | សុម៉ាលី | សិក្ខាបទធារី | សាលាបឋមសិក្សា សត្វពង | ស្រុកឈូក |
| ៦៤ | លោកស្រី | ឃុន | ពៅ | សិក្ខាបទធារី | សាលាបឋមសិក្សា ប៊ុនរ៉ានីហសនារាយណ៍ | ស្រុកឈូក |
| ៦៥ | លោកស្រី | ប៉ាល់ | សារី | សិក្ខាបទធារី | សាលាបឋមសិក្សា ក្រាំងរលួស | ស្រុកឈូក |
| ៦៦ | លោក | មាស | សំណាង | សិក្ខាបទធារី | សាលាបឋមសិក្សា វត្តជ័យខ្ពស់ | ស្រុកកំពង់ត្រាច |
| ៦៧ | លោក | ហែម | សុកសេដ្ឋា | សិក្ខាបទធារី | សាលាបឋមសិក្សា អង្គសុរភី | ស្រុកកំពង់ត្រាច |
| ៦៨ | លោកស្រី | ឃុយ | សារឿង | សិក្ខាបទធារី | សាលាបឋមសិក្សា ដំណាក់ក្រឡាញ់ | ស្រុកកំពង់ត្រាច |
| ៦៩ | លោក | ហុក | ទ្រី | សិក្ខាបទធារី | វិទ្យាល័យ ព្រះបិតាជាតិ | ស្រុកកំពង់ត្រាច |
| ៧០ | លោក | កែវ | តំ | សិក្ខាបទធារី | វិទ្យាល័យ អង្គសុរភី | ស្រុកកំពង់ត្រាច |
| ៧១ | លោក | មា | ស៊ាង | សិក្ខាបទធារី | អនុវិទ្យាល័យ កំពូលមាស | ស្រុកកំពង់ត្រាច |
| ៧២ | លោក | ជូ | ញ | សិក្ខាបទធារី | វិទ្យាល័យ ហ៊ុន សែនបរិវាស | ស្រុកបន្ទាយមាស |
| ៧៣ | លោក | អ៊ឹង | សារ៉ាន់ | សិក្ខាបទធារី | វិទ្យាល័យ ហ៊ុន សែនបរិវាស | ស្រុកបន្ទាយមាស |
| ៧៤ | លោក | ខាន់ | ឈឹង | សិក្ខាបទធារី | វិទ្យាល័យ ទូកមាស | ស្រុកបន្ទាយមាស |
| ៧៥ | លោក | អ៊ូច | សុភ័ណ្ឌ | សិក្ខាបទធារី | វិទ្យាល័យ ទូកមាស | ស្រុកបន្ទាយមាស |
| ៧៦ | លោក | សុខ | សំណាង | សិក្ខាបទធារី | វិទ្យាល័យ ទូកមាស | ស្រុកបន្ទាយមាស |
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ០៩ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ឧបដ្ឋានសាលា កុដិថ្មចំនួន០២ខ្នង ក្លោងទ្វារ របងវត្ត រោងទទួលភ្ញៀវចំនួន០២ និងជួសជុលព្រះវិហារ នៅ**វត្តសង្កែ** ស្ថិតនៅក្នុងឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក‑ មេដាយមាសស្ថាបនាជាតិចំនួន ០៦ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ស្រី សាលី** | គង់នៅវត្តសង្កែ | បច្ច័យចំនួន ១៣.៦០០ ដុល្លារ |
| ២-ព្រះតេជគុណ | **ចោ សុជា** | ព្រះចៅអធិការវត្តសង្កែ | បច្ច័យចំនួន ១២.៩២០ ដុល្លារ |
| ៣-លោក | **នួន សំអ៊ាន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៥.៧២០ ដុល្លារ |
| ៤-លោក | **សំ ពុត** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៣.៤៣០ ដុល្លារ |
| ៥-ឧបាសិកា | **យិន អ៊ុត** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១២.៧៥០ ដុល្លារ |
| ៦-ឧបាសិកា | **រស់ សឿន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១២.៤០០ ដុល្លារ |

**ខ‑ មេដាយសំរិទ្ធស្ថាបនាជាតិចំនួន ០៣ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-លោក | **ម៉ុក សុវណ្ណា** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ៣.៤៤០ ដុល្លារ |
| ២-លោក | **ស៊ុន សារី** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ៣.២០០ ដុល្លារ |
| ៣-លោក | **ផាន រតនា** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ៣.១៧៤ ដុល្លារ |

**មាត្រា ២.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តស្វាយរៀង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .–**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ផ្តល់ជូនសប្បុរជននៅក្នុង និងក្រៅប្រទេសចំនួន ០៤ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង សាលារៀន សាលាធម្មសភា សាលាគណ កន្លែងទទួលភ្ញៀវ និងកន្លែងចូលបច្ច័យ នៅ**វត្តប្រាសាទមង្គល** ស្ថិតនៅក្នុងឃុំសីង្ហ ស្រុកសំរោង ខេត្តតាកែវ ដែលមានរាយនាមដូចខាងក្រោម :

១-លោកស្រី **ឃូ ម៉េងជូ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៥.០២០ ដុល្លារ
២-លោក **ឡេង ឃុយឃាង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៣.២១០ ដុល្លារ
៣-លោក **គីម ហេង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១២.២៥៥ ដុល្លារ
៤-លោក **ស៊ឹម ថន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១១.៥០០ ដុល្លារ

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តតាកែវ និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៩១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១** : ត្រូវបានតែងតាំងលោកស្រី **ម៉ែន សុមតា** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជំនួសលោក **ចាន់ ស៊ី** ដែលចូលនិវត្តន៍ ។

**មាត្រា២**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ១៩៧ .អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរ និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យ លេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១** : ត្រូវបានផ្ទេរភារកិច្ច និងតែងតាំង លោក អ៊ុច តឹមយ៉ុន ពីទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណៈរដ្ឋសិង្ហបុរី ឲ្យទទួលភារកិច្ចថ្មីជាទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋប្រជាមានិតចិន ដែលមានទីតាំងនៅតំបន់ស្វយ័តក្វាងស៊ីឈ្វង។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១១
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៥៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនមន្ត្រីថ្នាក់ដឹកនាំនៃទីក្រុង **គីតាគ្យូស៊ូ** ( KitaKyushu ) និងមន្ត្រីបច្ចេកទេស នៃរដ្ឋាករទឹកគីតាគ្យូស៊ូ ប្រទេសជប៉ុន ចំនួន ១០រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យទឹកស្អាតដោយបានខិតខំជួយបង្ហាត់បង្រៀន នូវបច្ចេកទេសវិស័យទឹកស្អាតដល់មន្ត្រីនិយោជិតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងតាមបណ្តាខេត្តក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម៖

| | |
|---|---|
| ១-Kitahashi Kenji | Mayer of Kitakyushu City |
| ២-Yoshida Kazuhiko | Existing Director General |
| ៣-Yano Hiroshi | Existing Director General |
| ៤-Mori Kazumasa | Retired Director |
| ៥-Yoshida Toshiyuki | Retired Director |
| ៦-Kubota Kazuya | ប្រធានទីប្រឹក្សាស្តីទីនៃអង្គការ JICA ទទួលបន្ទុកគំរោង |
| ៧-Kiyama Satoshi | មន្ត្រីគ្រប់គ្រងគំរោង |
| ៨-Takayama Kazuo | មន្ត្រីជំនាញ |
| ៩-Kagata Katsutoshi | ប្រធានទីប្រឹក្សាស្តីទីនៃអង្គការ JICA ទទួលបន្ទុកគំរោង |
| ១០-Ishii Hideo | មន្ត្រីជំនាញ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៥៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី ថ្នាក់ សេនា** ចំនួន ០៤គ្រឿង ជូនទីប្រឹក្សាអន្តរជាតិ របស់អង្គការ CIDA/Canada Finnmap, GTZ ដែលបានខិតខំប្រឹងប្រែង រួមចំណែកក្នុងការអនុវត្តកម្មវិធី អនុវិស័យរដ្ឋបាលដីធ្លី ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | លោក | Ron | Hewitt | Project Director CLASP-Canada |
| ២- | អ្នកស្រី | Linda | Wishart | Counselor Development-Canada |
| ៣- | លោក | Jukka | Pekka | Legal Advisor Finnmap |
| ៤- | លោក | George | Cooper | Legal Advisor GTZ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ [illegible] ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ១៧ សសរ**

# សេចក្តីសំរេច
## ស្តីពីការបង្កើតក្រុមការងារសម្របសម្រួល ជាមួយក្រុមអ្នកសង្កេតការណ៍ឥណ្ឌូនេស៊ីមកត្រួតពិនិត្យបទឈប់បាញ់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១** : ត្រូវបានបង្កើតក្រុមការងារសម្របសម្រួលជាមួយក្រុមសង្កេតការណ៍ឥណ្ឌូនេស៊ីមកត្រួតពិនិត្យបទឈប់បាញ់គ្នា ដូចមានសមាសភាពខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តមនាយឧត្តមសេនីយ៍ | **ទៀ បាញ់** | រដ្ឋមន្ត្រីក្រសួងការពារជាតិ | ប្រធាន |
| ២- | ឯកឧត្តម | **អ៊ុក រ៉ាប៊ុន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៣- | ឯកឧត្តម | **ប្រាក់ សុខុន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការទីស្តីពីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- | ឯកឧត្តមនាយឧត្តមសេនីយ៍ | **នាង ផាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៥- | ឯកឧត្តម | **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៦- | ឯកឧត្តមនាយឧត្តមសេនីយ៍ | **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ៧- | ឯកឧត្តមនាយឧត្តមសេនីយ៍ | **គន់ គីម** | អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៨- | ឯកឧត្តមនាយឧត្តមសេនីយ៍ | **ហ៊ីង ប៊ុនហៀង** | អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ មេបញ្ជាការបញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ៩- | ឯកឧត្តមនាយឧត្តមសេនីយ៍ | **សៅ សុខា** | អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |

**ប្រការ ២** : ក្រុមការងារនេះមានភារកិច្ចសម្របសម្រួល និងផ្តល់លក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ការបំពេញភារកិច្ចរបស់ក្រុមអ្នកសង្កេតការណ៍ឥណ្ឌូនេស៊ី ស្របតាមលក្ខខណ្ឌប្រតិបត្តិរបស់ក្រុមនេះ ។

**ប្រការ ៣** : ក្រុមការងារត្រូវរាយការណ៍ជូនសម្តេចនាយករដ្ឋមន្ត្រីអំពីការវិវត្តន៍នៃស្ថានភាពការណ៍នៅតំបន់ ប៉ះពាល់ និងស្នើសុំការណែនាំតាមការចាំបាច់ពីសម្តេចនាយករដ្ឋមន្ត្រី ។

**ប្រការ ៤** : ក្រុមការងារមានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយ ដែលមានមុខងារជាសេនាធិការជូនក្រុមការងារ ដើម្បីធ្វើទំនាក់ទំនងជាអចិន្ត្រៃយ៍ជាមួយក្រុមអ្នកសង្កេតការណ៍ឥណ្ឌូនេស៊ី និងដោះស្រាយការងារតាមការជាក់ស្តែង ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល**</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៨. សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការរៀបចំស្ដារ និងអភិវឌ្ឍន៍ បឹងប្រាក់

- យោងតាមសំណូមពរនិងការងារចាំបាច់

**សម្រេច**

**ប្រការ១**.- ត្រូវបានបង្កើតគណៈកម្មការរៀបចំស្តារនិងអភិវឌ្ឍន៍ **បឹងប្រាក់** ស្ថិតក្នុងវត្តព្រៃអង្គក្នុង ឃុំដូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **លឹម គានហោ** | រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | ប្រធាន |
| ២-ឯកឧត្តម | **ហ៊ឹម ឆែម** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣-ឯកឧត្តម | **ហ៊ុន ណេង** | អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម | អនុប្រធាន |
| ៤-ឯកឧត្តម | **ស៊ឹម វណ្ណា** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥-លោក | **ឡុង ឆាប** | អភិបាលនៃគណៈអភិបាលស្រុកពញាក្រែក | សមាជិក |

**ប្រការ២**.- គណៈកម្មការនេះមានភារកិច្ចសហការ ជាមួយក្រសួងធនធានទឹកនិងឧតុនិយម ដើម្បីក្រសួងសិក្សាលើកគម្រោងចំណាយ ក្នុងការស្តារ និងអភិវឌ្ឍន៍ **បឹងប្រាក់** នេះឲ្យក្លាយជារមណីយដ្ឋានបុរាណប្រវត្តិសាស្ត្រទេសចរណ៍ ។ គណៈកម្មការនេះអាចបង្កើតអនុគណៈកម្មការជំនាញជាជំនួយការតាមការចាំបាច់ ។

**ប្រការ៣**. សេចក្តីសម្រេចនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមីនា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>ចម្លងជូន:</u>
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងធនធានទឹកនិងឧតុនិយម
- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- ក្រសួងទេសចរណ៍
- សាលាខេត្តកំពង់ចាម
- ឯកសារ-កាលប្បវត្តិ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៥.សសរ

# សេចក្តីសម្រេច
# ស្តីពីការបង្កើតក្រុមការងាររៀបចំពាក្យបណ្តឹងបញ្ហាប្រាសាទព្រះវិហារ ទៅតុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១** ៖ ត្រូវបានបង្កើតក្រុមការងាររៀបចំពាក្យបណ្តឹងបញ្ហាប្រាសាទព្រះវិហារ ទៅតុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេ ដូចមានសមាសភាពខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ហោ ណាំហុង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- ឯកឧត្តម | **វ៉ា គឹមហុង** | ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការព្រំដែននៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣- ឯកឧត្តម | **អូន ព័ន្ធមុនីរ័ត្ន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- ឯកឧត្តម | **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥- ឯកឧត្តម | **អ៊ុជ គឹមអន** | ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋបារាំង | សមាជិក |

**ប្រការ ២** ៖-ក្រុមការងារមានភារកិច្ច រៀបចំពាក្យបណ្តឹង និងឯកសារយោងទៅតុលាការយុត្តិធម៌អន្តរជាតិ ទីក្រុងឡាអេ ដើម្បីធ្វើការបកស្រាយសាលក្រមថ្ងៃទី ១៥ មិថុនា ១៩៦២ ។

-ក្រុមការងារអាចជ្រើសរើស និងជួលអ្នកច្បាប់បរទេស ព្រមទាំងចាត់វិធានការចាំបាច់នានា ដើម្បីធានាជោគជ័យនៃភារកិច្ចខាងលើ ។

-ក្រុមការងារត្រូវបន្តទំនាក់ទំនងការងារជាមួយតុលាការយុត្តិធម៌អន្តរជាតិស្របតាមនីតិវិធីរបស់តុលាការរហូតដល់ទទួលបានលទ្ធផលបញ្ចប់នៃការបកស្រាយសាលក្រមខាងលើ ។

-ប្រធានក្រុមការងារ អាចជ្រើសរើសមន្ត្រីមានសមត្ថកិច្ចផ្សេងៗទៀត ដើម្បីជួយដល់ក្រុមការងារ។

**ប្រការ ៣** ៖ ក្រុមការងារត្រូវរាយការណ៍ជូនសម្តេចនាយករដ្ឋមន្ត្រីអំពីការវិវត្តន៍នៃការងារនិងស្នើសុំការណែនាំតាមការចាំបាច់ ពីសម្តេចនាយករដ្ឋមន្ត្រី ។

**ប្រការ ៤** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ០៧.សរណន**

# សារាចរណែនាំ
## ស្ដីពី
## ការរៀបចំទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៣ ឆ្នាំ២០១១

អនុវត្តតាមស្មារតីអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៦ ស្ដីពីការបង្កើតទិវាវប្បធម៌ជាតិ រាជរដ្ឋាភិបាលបានកំណត់យកថ្ងៃទី៣មីនា ជារៀងរាល់ឆ្នាំ សម្រាប់ប្រារព្ធ **"ទិវាវប្បធម៌ជាតិ"** នៃព្រះរាជាណាចក្រកម្ពុជា។

ជានិច្ចកាលរាជរដ្ឋាភិបាលកម្ពុជាតែងយកចិត្តទុកដាក់ ថែរក្សា ការពារ លើកតម្កើងកេរដំណែល និងអភិវឌ្ឍសកម្មភាពវប្បធម៌គ្រប់ជំនាញនៅតាមមូលដ្ឋាន ពិសេសតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ដើម្បីឱ្យមានការរីកចម្រើនខាងសង្គម សេដ្ឋកិច្ច និងជីវភាព តាមរយៈការជំរុញផលិតកម្មសិប្បកម្មវប្បធម៌ ដោយលើកទឹកចិត្តឱ្យមានការបង្កើតស្នាដៃថ្មី និងផ្សព្វផ្សាយអំពីផលិតផលវប្បធម៌ខ្មែរដ៏សម្បូរបែប។ អប់រំអំពីវប្បធម៌ សីលធម៌ដ៏ល្អថ្លៃថ្លារបស់ជាតិ និងទប់ស្កាត់នូវការហូរចូលនៃវប្បធម៌អវិជ្ជមាន ដើម្បីកាត់បន្ថយសកម្មភាពមិនល្អក្នុងស្រទាប់យុវជន និងកុមារដែលធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ដ៏ល្អផូរផង់របស់ជាតិ។

ផ្អែកតាមបរិបទខាងលើ ក្នុងដំណាក់កាលដែលធនធានសម្បត្តិវប្បធម៌ដ៏សម្បូរបែបរបស់យើងត្រូវបាន និងកំពុងទទួលរងនូវផលប៉ះពាល់ដោយសារកត្តាមួយចំនួនដូចជា: កត្តាសង្គ្រាម កត្តាធម្មជាតិ កត្តាមនុស្ស ភាពចំណាស់នៃប្រាសាទ កត្តាលំហូរចូលឥតឈប់ឈរនៃវប្បធម៌អវិជ្ជមាន និងដោយយល់ថា វប្បធម៌ គឺជាព្រលឹង និងជាអត្តសញ្ញាណជាតិ ដែលមានតម្លៃមហាសាលពុំអាចកាត់ថ្លៃបាន ជាប្រភពធនធានរួមរបស់មនុស្ស ជា**ស៊ីម៉ង់រស់**សម្រាប់ផ្សារភ្ជាប់ទំនាក់ទំនង ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ ពីសហគមន៍មួយទៅសហគមន៍មួយ ពីប្រទេសមួយទៅប្រទេសមួយ ដែលជាកត្តាដ៏ចាំបាច់បំផុតក្នុងការនាំមកនូវសាមគ្គីភាព សន្តិភាព សុខដុមភាព ដែលជាកម្លាំងគ្រឹះ និងជាប្រភពមិនចេះរីងស្ងួត នៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយនិរន្តរភាពនោះ ការរួមគ្នា ដើម្បី **សុវត្ថិភាព និរន្តរភាព សុខដុមភាព** និង**វឌ្ឍនភាព** នៃវប្បធម៌ ក្នុងគោលដៅ **កម្ពុជា : ព្រះរាជាណាចក្រនៃវប្បធម៌** គឺជាកិច្ចការដ៏ចាំបាច់ចំពោះមុខសម្រាប់យើងទាំងអស់គ្នា។

អនុលោមតាមស្មារតីខាងលើ នៅឆ្នាំ២០១១នេះ រាជរដ្ឋាភិបាលកម្ពុជាបន្តរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៣ ដោយសម្រេចកំណត់យកប្រធានបទ " **អ្វីៗនាំងអស់ដើម្បីសុវត្ថិភាពវប្បធម៌** " ក្នុងគោលបំណងធ្វើឱ្យប្រជាជនទូទាំងប្រទេស:

- ចូលរួមកាន់តែសកម្មថែមទៀតក្នុងការថែរក្សា ការពារ មតិកវប្បធម៌របស់ជាតិឱ្យទទួលបាននូវសុវត្ថិភាព
- ស្គាល់ និងយល់ដឹងកាន់តែច្បាស់ពីភាពសម្បូរបែបនៃបេតិកភណ្ឌវប្បធម៌ ដែលជាប្រភពមិនចេះរីងស្ងួតក្នុងការបង្កើតការងារ និងបង្កើនកាលានុវត្តភាពសម្រាប់ទាញយកប្រាក់ចំណូលប្រកបដោយប្រសិទ្ធភាព
- ប្រើប្រាស់សក្តានុពលវប្បធម៌ ធ្វើជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍសង្គម តាមរយៈការបង្កើតសេវាកម្ម និង ផលិតផលវប្បធម៌សម្រាប់គោលដៅពាណិជ្ជកម្ម និងទេសចរណ៍

ដើម្បីឱ្យការរៀបចំទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៣ ឆ្នាំ២០១១ ក្រោមប្រធានបទ "**អ្វីៗនាំងអស់ដើម្បីសុវត្ថិភាពវប្បធម៌**" ប្រព្រឹត្តទៅប្រកបដោយជោគជ័យស្របតាមគោលបំណងខាងលើ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវសេចក្តីណែនាំដូចខាងក្រោម :

១-គ្រប់លំនៅដ្ឋាន គ្រប់ក្រសួង-ស្ថាប័ន អាជ្ញាធរដែនដី សហគ្រាសរដ្ឋ និងឯកជនគ្រប់លំដាប់ថ្នាក់ ត្រូវលើកទង់ជាតិ ទង់ជ្វាលា បដាពាក្យស្លោក បិទផ្សាយអាហ្វីសតាមដងផ្លូវសាធារណៈ ទីលានសាធារណៈ អង្គភាព និងលំនៅដ្ឋានរបស់ខ្លួនឱ្យបានព្រមៗគ្នា ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ ។

២-ក្រសួងព័ត៌មានត្រូវរៀបចំកម្មវិធីផ្សាយពិសេសតាមវិទ្យុ-ទូរទស្សន៍ជាតិ និងឯកជន កាសែត និងទស្សនាវដ្តី នូវខ្លឹមសារនៃទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៣ និងឯកសារពាក់ព័ន្ធ ដើម្បីឱ្យសាធារណជនចូលរួមកាន់តែសកម្មថែមទៀត ក្នុងការថែរក្សា ការពារ និងលើកស្ទួយសម្បត្តិវប្បធម៌ ស្របតាមប្រធានបទ "**អ្វីៗនាំងអស់ដើម្បីសុវត្ថិភាពវប្បធម៌**"។

៣-ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបើកកម្មវិធីប្រកួតប្រជែងក្នុងមជ្ឈដ្ឋានសិស្ស និស្សិត តាមរយៈការបង្កើត " **សំណួរ ចម្លើយ** " ស្តីពី ការរួមគ្នាធ្វើយ៉ាងណាដើម្បីឱ្យបេតិកភណ្ឌវប្បធម៌ជាតិ មាន **សុវត្ថិភាព** មាន **និរន្តរភាព** មាន **សុខដុមភាព** និងមាន **វឌ្ឍនភាព**។

៤-ក្រសួងទេសចរណ៍ ត្រូវចែកផ្សាយរាល់ឯកសារ ស្តីពីទេសចរណ៍វប្បធម៌ និងឯកសារដែលពាក់ព័ន្ធជូនគ្រប់ទីភ្នាក់ងារទេសចរណ៍ ប្រតិបត្តិករទេសចរណ៍គ្រប់ប្រភេទ ដើម្បីពង្រីកទីផ្សារ និងបង្កើនភាពទាក់ទាញ ។

៥-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវណែនាំដល់គ្រប់ឯកអគ្គរាជទូត អគ្គកុងស៊ុល និងកុងស៊ុលកិត្តិយស នៃព្រះរាជាណាចក្រកម្ពុជានៅបរទេសឱ្យរៀបចំទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៣ ឆ្នាំ ២០១១ តាមលទ្ធភាពជាក់ស្តែង ។

៦-ក្រសួងធម្មការ និងសាសនា ត្រូវបំផុសចលនាព្រះសង្ឃ និងគ្រប់សាសនិកឱ្យរៀបចំកម្មវិធីផ្សព្វផ្សាយខ្លឹមសារទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៣ នៅតាមទីវត្តអារាម ព្រះវិហារ មណ្ឌលវិបស្សនា និងទីសក្ការៈផ្សេងៗតាមការជាក់ស្តែង ។

៧-អាជ្ញាធរ "**អប្សរា**" អាជ្ញាធរ "**ព្រះវិហារ**" ត្រូវរៀបចំពិធីមីទ្ទិញអបអរទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៣ ឆ្នាំ២០១១ នៅតាមរមណីយដ្ឋានប្រាសាទបុរាណផ្ទាល់តាមការជាក់ស្តែង ។

៨-អាជ្ញាធរដែនដី រាជធានី/ខេត្ត ត្រូវជួយឧបត្ថម្ភគាំទ្រ និងបង្កលក្ខណៈឱ្យមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំពិធីមិទ្ទិញអបអរទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៣ ឆ្នាំ២០១១ នៅក្នុងដែនដីរបស់ខ្លួន ដោយមានកម្មវិធីសម្តែងសិល្បៈទស្សនីយភាពជូនសាធារណជនទស្សនាកម្សាន្តស្របតាមប្រធានបទ "**អ្វីៗទាំងអស់ដើម្បីសុខត្ថិភាពវប្បធម៌** "។ ដោយឡែកខេត្តចំនួន៦គឺៈ ខេត្តតាកែវ ខេត្តកំពត ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តកំពង់ធំ និង ខេត្តបាត់ដំបង ត្រូវប្រារព្ធពិធីនេះនៅនឹងទីប្រាសាទផ្ទាល់ ដោយណែនាំបំផុសឱ្យប្រជាជន និស្សិត និង សិស្សានុសិស្ស ដែលចូលរួមសម្អាតទីប្រាសាទក្នុងន័យបញ្ជាក់ពីស្មារតីស្នេហាសម្បត្តិបេតិកភណ្ឌជាតិ។

៩-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវមានផែនការណែនាំបែងចែកកងកម្លាំងសម្រាប់ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅតាមទីកន្លែងប្រារព្ធពិធីអបអរទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៣ ឱ្យមានសុវត្ថិភាព។

១០-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវធ្វើជាលេខាធិការដ្ឋានក្នុងការរៀបចំឯកសារឃោសនាផ្សព្វផ្សាយបម្រើឱ្យទិវាវប្បធម៌ជាតិទាំងមូល និងដឹកនាំឱ្យគ្រប់រាជធានី/ខេត្ត រៀបចំទិវាវប្បធម៌ជាតិក្នុងភូមិសាស្ត្ររបស់ខ្លួនជាពិសេស ត្រូវបែងចែកមន្ត្រីជាន់ខ្ពស់ចុះតាមបណ្តារាជធានី/ខេត្ត ដើម្បីសហការជាមួយអាជ្ញាធរដែនដីរៀបចំប្រារព្ធពិធីនេះ។

១១-គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អង្គភាព រោងចក្រ សហគ្រាសរដ្ឋ និងវិស័យឯកជនទាំងអស់នៅទូទាំងប្រទេស ត្រូវរៀបចំអបអរសាទរទិវាវប្បធម៌ជាតិតាមខ្លឹមសារខាងលើ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីពេលទទួលបានខ្លឹមសារនៃសារាចរណែនាំនេះ សំដៅអនុវត្តឱ្យបានជោគជ័យកាន់តែប្រសើរឡើងថែមទៀតនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលអាណត្តិទី៤។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់អាជ្ញាធរជាតិ
-សាលារាជធានី និងគ្រប់ខេត្ត
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៣ សហវ-អពដ

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១១

# សេចក្តីជូនដំណឹង

## ស្តីពីការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំជាប់ពន្ធ ២០១០

អនុលោមតាមមាត្រា ៥ និងមាត្រា ២៩ នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករ របស់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ទាំងអស់ សូមជ្រាបអំពីកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ២០១០ ដូចខាងក្រោម :

១- សហគ្រាសដែលប្រើប្រាស់ឆ្នាំជាប់ពន្ធតាមឆ្នាំប្រតិទិន (០១ ខែមករា ដល់ ៣១ ខែធ្នូ) ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១០ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១ នៅរដ្ឋបាលសារពើពន្ធដែលមានសមត្ថកិច្ចគ្រប់គ្រងប្រមូលពន្ធលើសហគ្រាស ។

២- សហគ្រាសដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំយ៉ាងយឺតបំផុតក្នុងរយៈវេលា ៣ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធ ។

៣- សហគ្រាសដែលមានសាខាច្រើន ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានមកពីលទ្ធផលសរុបរួមបញ្ចូលគ្នារបស់គ្រឹះស្ថានជាគោលដើមនិងគ្រប់សាខាទាំងអស់ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍លទ្ធផលចំណេញ-ខាតរបស់សាខានីមួយៗ ។ គ្រឹះស្ថានដែលជាសាខានីមួយៗ ត្រូវប្រកាសលទ្ធផលចំណេញ-ខាត សាខារបស់ខ្លួនតាមគំរូលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងដាក់ជូនរដ្ឋបាលសារពើពន្ធនៅទីកន្លែងដែលសាខាជាប់ទាក់ទិននីមួយៗតាំងនៅ ។

៤- សហគ្រាសដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គលគ) ច្រើន ឬ អនុវត្តគម្រោងដទៃទៀតច្រើនដែលជាគម្រោង គលគ ផង និងមិនមែនជា គលគ ផង ហើយដែលទទួលបានការលើកលែងពន្ធលើប្រាក់ចំណេញខុសគ្នា ឬត្រូវជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាខុសៗគ្នា ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំដូចមានចែងក្នុងចំណុច ១ ដល់ ៣ ខាងលើ និងត្រូវអនុវត្តតាមការណែនាំបន្ថែមដោយឡែករបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៥- ចំពោះតំណាងអ្នកជាប់ពន្ធដែលទទួលបន្ទុក ធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ ដាក់លិខិតប្រកាសពន្ធប្រចាំខែ ប្រចាំឆ្នាំ ជំនួសមុខឱ្យអ្នកជាប់ពន្ធ ត្រូវមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធ ដូចមានចែងក្នុងមាត្រា ១០៦ នៃច្បាប់ស្តីពីសារពើពន្ធ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមថ្លែងអំណរគុណចំពោះសហគ្រាសមួយចំនួន ដែលកន្លងមកបំពេញលិខិតប្រកាសពន្ធបានត្រឹមត្រូវ និងដាក់ជូនរដ្ឋបាលសារពើពន្ធទាន់ពេលវេលា ។

ដើម្បីសម្របសម្រួលក្នុងការបំពេញលិខិតប្រកាសឱ្យបានត្រឹមត្រូវ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសៀវភៅពន្យល់ណែនាំសម្រាប់បំពេញលិខិតប្រកាស និងបង្កើតទម្រង់លិខិតប្រកាសជា software ។ ក្នុងករណីលោក-លោកស្រី មានចម្ងល់ផ្សេងៗ សូមទាក់ទងជាមួយការិយាល័យសេវាអ្នកជាប់ពន្ធ នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្ត ដែលទាក់ទិន ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមនិងជឿជាក់ថា លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាស ពិតជាយកចិត្តទុកដាក់ អនុវត្តសេចក្តីជូនដំណឹងនេះបានល្អប្រសើរ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ១៩៧៨ ឧរ៉ថ.ភ១-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ ២៦៩៨ /១០ គ.វ.ក ចុះថ្ងៃទី២៩.១២.២០១០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន សេន ហ្សាន ស៊ូ (ខេមបូឌា) ចុះថ្ងៃទី ១៨.១២.២០១០

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន សេន ហ្សាន ស៊ូ (ខេមបូឌា) តំណាង ដោយ លោក CHIU PO-YU សញ្ជាតិកាណាដា អាយុ៣៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ JX342387 ចុះថ្ងៃទី៣០.០៣.២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ #82 Shin Yi St. Feng Yuan City Tai Chung Taiwan. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Rev.4 Code |
|---|---|
| ស្បែកជើង | ១៥២០ |

-ផ្លាកឈ្មោះរោងចក្រ ៖ *"សេន ហ្សាន ស៊ូ (ខេមបូឌា) (SEN ZHAN SHOES (CAMBODIA) CO., LTD.)"*

-ទីតាំងរោងចក្រ ៖ *"អាគារលេខ ៦០ដេ ផ្លូវលេខ១៩៦៨ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។ ៣៨

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ៕

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ...២៧២ ឧស្ស.រ៉ែ.ថព - ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ ០១០ /១០ ក.ត.ស.ព ចុះថ្ងៃទី១០.០២.២០១០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស៊ីន ស៊ី អេក អិន ហុង (ខេមបូឌា ) ប្លាស្ទិក អ៊ិនដាស្ទ្រី ចុះថ្ងៃទី ២៨.០៩.២០០៩

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ស៊ីន ស៊ី អេក អិន ហុង (ខេមបូឌា ) ប្លាស្ទិក អ៊ិនដាស្ទ្រី តំណាងដោយ លោក YANG, CHI-CHIN សញ្ជាតិចិន(តៃវ៉ាន់) អាយុ៥៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 132479954 ចុះថ្ងៃទី២៨.០៩.២០០១ មានអាសយដ្ឋានបច្ចុប្បន្ន៖ Yi Duan 6 gang 23 No. 1, 8 Floor, Sha Tian Road, Wang Tian Village, Tatu Hsiang, Tai Chung, Taiwan. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ ប្លាស្ទិក លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Rev.4 Code |
|---|---|
| បាត ពុម្ព ទ្រនាប់ ស្បែកជើង ពីប្លាស្ទិក | ២២២០ |

-ផ្លាកឈ្មោះរោងចក្រ ៖ *"ស៊ីន ស៊ី អេក អិន ហុង (ខេមបូឌា) ប្លាស្ទិក អ៊ិនដាស្ទ្រី (SIN CHN HONG (CAMBODIA) PLASTICS INDUSTRY CO., LTD.)"*

-ទីតាំងរោងចក្រ ៖ *"តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ឃុំភ្លើងឆេះរទេះ ខណ្ឌដង្កោ រាជធានីភ្នំពេញ និងឃុំកន្ទោក-ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្តាល"*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។ /.

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលារាជធានីភ្នំពេញ

-សាលាខេត្តកណ្តាល

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៨ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ